ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់

និងប្រព័ន្ធយុត្តិធម៌

អង្គភាពគ្រប់គ្រងគម្រោង

# របាយការណ៍

# ក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា

ឆ្នាំពីពាន់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទី ម្ភៃប្រាំបី វេលាម៉ោងដប់ប្រាំ នៅសាលប្រជុំរបស់អង្គភាពគ្រប់គ្រងគម្រោងនៃ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ មានរៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅ កម្ពុជា ក្រោមអធិបតីភាពរបស់ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានស្តីទីអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងពិភាក្សាការអនុម័តផែនការការងារ និងថវិកាប្រចាំឆ្នាំ ២០០៧ នៃគម្រោង សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ឧបត្ថម្ភដោយអង្គការ UNDP។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម អង្គ វង្សវឌ្ឍានា បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាសមាជិកក្រុមប្រតិបត្តិគម្រោង តំណាងក្រសួងពាក់ព័ន្ធ និងជាមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមបឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនោះ ។

ជាបន្ទាប់ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោង និងជានាយកគម្រោងថ្នាក់ជាតិ សម្រាប់គម្រោង សិទ្ធិទទួលបានយុត្តិធម៌ បានបង្ហាញជូនពីមុខងារ និងភារកិច្ចរបស់ក្រុមប្រតិបត្តិគម្រោង Project Executive Group (PEG) និងរាយការណ៍ជូននូវរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តគម្រោងសិទ្ធិទទួលបាន យុត្តិធម៌

នៅកម្ពុជាសម្រាប់ឆ្នាំ **២០០៦** កន្លងមក ដោយមានឯកសារដាក់ជូនអង្គប្រជុំផងដែរ ។ គម្រោងដែលបានចាប់ផ្ដើមតាំងពីខែ មេសា ឆ្នាំ **២០០៦**មកនោះមាន ៖

1- គម្រោងទី១ ៖ លើកកំពស់ការយល់ដឹងសិទ្ធិមនុស្សនៅកំរិតសហគមន៍ ដែលមានឯកឧត្ដម **សួង លាងហៃ** ជាអ្នកគ្រប់គ្រងគម្រោង ។

2- គម្រោងទី២ ៖ ធ្វើឱ្យមានចិរភាពនៃរាជកិច្ច ដែលមានលោកស្រីជំទាវ **ឆាយ ទ៉ាន់ឡឿន** ជាអ្នកគ្រប់គ្រង គម្រោង ។

3- គម្រោងទី៣ ៖ ការផ្សព្វផ្សាយសេចក្ដីសម្រេចរបស់តុលាការ និងសាលដីការរបស់តុលាការកំពូល ដែល មានឯកឧត្ដម **ឃីម ប៉ុន** ជាអ្នកគ្រប់គ្រងគម្រោង ។

4- គម្រោងទី៤ ៖ គឺការដោះស្រាយទិន្នន័យគ្រៅប្រព័ន្ធតុលាការ ដែលមានលោក **សុខ ម៉ូរ៉ា** ពីក្រសួងយុត្តិធម៌ និងលោក **ឌុន ម៉ុនថាល់** ជាអ្នកគ្រប់គ្រងគម្រោង ។

ទាក់ទងនឹងដំណើរការនៃគម្រោងទាំងបួននេះ គម្រោងទីបី(៣) ស្ដីពីការផ្សព្វផ្សាយសេចក្ដីសម្រេចរបស់តុលាការ ខាង UNDP មិនទាន់មានថវិកាសម្រាប់គម្រោងនេះនៅឡើយទេ ។

ឯកឧត្ដម **អង្គ វង្សវឌ្ឍានា** បានលើកឡើងពីបញ្ហាគម្រោងថវិការបស់ UNDP កន្លងមក សម្រាប់ឆ្នាំ **២០០៦** ដោយអញ្ជើញតំណាង UNDP មកធ្វើការរាយការណ៍លំអិតអំពីខ្ទង់ចំណាយទៅលើគម្រោងតូចៗទាំងឡាយ ជូនអង្គប្រជុំបាន ជ្រាប។

លោក **កុយ ឆាម** តំណាង UNDP បានរាយការណ៍ថា ប្រាក់ដែលបានចាយលើគម្រោងកន្លងមកមានចំនួន **៣៣៨◌្ស៦៥៨.៤២** ដុល្លារ ក្នុងនោះមានការចំណាយលើបុគ្គលិក ថ្លៃឈ្នួលរថយន្ត ការស្រាវជ្រាវ ការធ្វើដំណើររបស់ បុគ្គលិកគម្រោង និងថ្លៃឧបករណ៍គមនាគមន៍ជាដើម ចំនួនទឹកប្រាក់ដែលនៅសល់ពីការអនុវត្តន៍គម្រោងកាលពីឆ្នាំ **២០០៦** កន្លងមកនោះនៅសល់ **៥◌្ស១៣៩៧៥៨** ដុល្លារ ។ លោកក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរថា ជំនួយរបស់ UNDP មានពីរ យ៉ាង គឺ Nec (National Execution) & Dec (Direct Execution) ហើយគម្រោងរបស់យើងដែលអនុវត្តគឺ គម្រោង បែប Nec ដែលត្រូវអនុវត្តដោយផ្ទាល់ពីរដ្ឋាភិបាល។ បន្ថែមពីលើនេះលោកបានមានប្រសាសន៍ថា គម្រោងរបស់យើង មិនទាន់ឈានដល់ការ ផ្ដល់ជូនថវិកាឱ្យរដ្ឋាភិបាលគ្រប់គ្រងផ្ទាល់នៅឡើយ ព្រោះត្រូវធ្វើការវាយតម្លៃសមត្ថភាព

នៃអង្គភាពទទួលបន្ទុកគ្រប់គ្រងថវិកា របស់ស្ថាប័នរដ្ឋាភិបាលសិន។ លោកស្រី Anne-Isabelle-Degryse Blateau បាន បញ្ជាក់ថា ការវាយតម្លៃនឹងចាប់ផ្តើ នៅខែក្រោយនេះហើយ ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានលើកបង្ហាញពីគម្រោងថវិកាសម្រាប់ការចាយវាយក្នុងឆ្នាំ ២០០៧ ដូច តទៅ ៖

ទាក់ទិននឹងគម្រោងទីមួយគឺ កម្មវិធីលើកកំពស់ការយល់ដឹងសិទ្ធិមនុស្សនៅសហគមន៍ ដែលទទួលខុសត្រូវ

ដោយឯកឧត្តម **សួង លាងហៃ** គម្រោងថវិកាសម្រាប់ឆ្នាំ ២០០៧មានទឹកប្រាក់ចំនួន ៣០្ល៨២២.00 ដុល្លារ។ ចំណែក ខាងអាជ្ញាធរដោះស្រាយទំនាស់ដីធ្លីមានថវិកាចំនួន ១៣000 ដុល្លារ។ អង្គប្រជុំបានអនុម័តលើការស្នើរបស់អាជ្ញាធរ ដោះស្រាយទំនាស់ដីធ្លី សុំបង្វែរថវិកាទាំងនោះទៅធ្វើការបោះពុម្ពផ្សាយនីតិវិធីនៃការដោះស្រាយទំនាស់ដីធ្លី និងច្បាប់

ដែលពាក់ពន្ធ័ទៅនឹងរឿងនេះវិញ ។ ជាមួយគ្នានោះដែរ ឯកឧត្តមបានសុំសំណូមពរឱ្យអ្នកគ្រប់គ្រងគម្រោង និងជំនួយការ ហិរញ្ញវត្ថុនៃគម្រោងនីមួយៗធ្វើគម្រោងផែនការ និងចំណាយឱ្យច្បាស់លាស់សំរាប់ដាក់ជូននៅ UNDP។

លោក **សោម សិរីវឌ្ឍន៍** តំណាងតុលាការកំពូលបានមានប្រសាសន៍ថា ហេតុអ្វីបានជាមិនឃើញមានគម្រោងថវិកា សម្រាប់ការបោះពុម្ពសាលដីការរបស់តុលាការកំពូល សម្រាប់ឆ្នាំ ២០០៧ នេះ ?។

ឆ្លើយតបនឹងបញ្ហានេះ លោក **កុយ នាម** បានបញ្ជាក់ថា UNDP មានថវិកាស្តួចស្តើងពេកមិនអាចផ្តល់ជូនសម្រាប់ បោះពុម្ពសាលដីការរបស់តុលាការកំពូលបាននៅឡើយ។ ចំពោះគម្រោងទីពីរ ពាក់ពន្ធ័នឹងការធ្វើឱ្យមានចិរភាពនៃការបោះពុម្ពផ្សាយ រាជកិច្ចគម្រោងថវិកាក្នុងឆ្នាំ ២០០៧នេះ មានទឹកប្រាក់ចំនួន ៥៤,៣១២ ដុល្លារ។ ចំពោះបញ្ហាបោះពុម្ពរាជកិច្ចនេះខាង UNDP មានគម្រោងធ្វើការហ្វឹកហ្វឺនដល់បុគ្គលិកអគ្គនាយកដ្ឋានរាជកិច្ច និងជួយធ្វើផែនការការងារប្រចាំឆ្នាំ។ ចំពោះគម្រោងទីបួនពាក់ព័ន្ធ ដល់ការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ គម្រោងថវិកា សម្រាប់ឆ្នាំ ២០០៧ មានចំនួន ១១១,៣៧២ ដុល្លារ សម្រាប់ក្រសួង យុត្តិធម៌ និងក្រសួងមហាផ្ទៃ។ ទាក់ទិននឹងគម្រោងមួយទៀត គឺការគាំទ្រជាពិសេសទៅលើស្ត្រីភេទ ដែលអនុវត្តន៍ដោយក្រសួង យុត្តិធម៌ និងក្រសួងមហាផ្ទៃ មានទឹកប្រាក់ ចំនួន ២២,៧១៨ ដុល្លារ និងគម្រោងមួយទៀត គឺ

«ការគាំទ្រដល់ជនជាតិភាគតិច» ដែលត្រូវអនុវត្តន៍ ដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ មានថវិកាចំនួន ១៣៤,១៣០ ដុល្លារ ។

លោកស្រី Anne-Isabelle-Degryse Blateau, UNDP បាននិយាយអំពីអំពើហិង្សាក្នុងគ្រួសារមួយរបស់ ស្ត្រីជនជាតិភាគតិចម្នាក់នៅឯខេត្តរតនៈគិរី ដែលច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារនេះមិនអាចជួយនាងបាន។ លោកស្រីបានសុំអំពាវនាវឱ្យគម្រោងនេះមានដំណើរទៅមុខឱ្យបានរលូន ពីព្រោះគម្រោងនេះមានសារៈសំខាន់ណាស់សម្រាប់ជនជាតិភាគតិច ។

ឯកឧត្តម **អង្គ វង្សវឌ្ឍនា** ឆ្លើយតបនឹងលោកស្រី Isabelle ថា ក្រសួងយុត្តិធម៌ចង់ឱ្យការដោះស្រាយវិវាទក្រៅប្រព័ន្ធ តុលាការនេះបានទៅដល់ថ្នាក់មូលដ្ឋាននៅឆ្ងាយៗ ដូចជាខេត្តរតនៈគិរីនេះជាដើម ដូច្នេះឯកឧត្តមសុំឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធបន្ថែមទៀតជាមួយក្រសួងយុត្តិធម៌ ដើម្បីអនុវត្តន៍គម្រោងទាំងនេះ។

អង្គប្រជុំបានឯកភាពអនុម័តផែនការការងារ និងថវិកាប្រចាំឆ្នាំ ២០០៧ សម្រាប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌ ដោយឯកឆន្ទ ។

ជាទីបញ្ចប់ឯកឧត្តម **អង្គ វង្សវឌ្ឍនា** បានថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់អង្គប្រជុំទាំងមូល ដែល បានចូល រួមក្នុងកិច្ចប្រជុំនាថ្ងៃនោះ ប្រកបដោយបរិយាកាសស្និតស្នាលក្រៃលែង។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំមួយ និងសែសិបប្រាំនាទីល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០០៧*

**បានឃើញ និងឯកភាព**
**នាយកគ្រប់គ្រងគម្រោងថ្នាក់ជាតិ**

**អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង** **សេង រ៉ាន់ដា**

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
នាថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៧

១-ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២-ឯកឧត្តម ស៊ុយ ម៉ុងលាង នាយករងអង្គភាពគ្រប់គ្រងគម្រោង គ.ក.ច.ន.យ

៣- ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង

៤- លោក ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង

៥- ឯកឧត្តម ដៃ សុខខេង ប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ គ.ក.ច.ន.យ

៦- លោក ប៊ូន សុមុនី ប្រធានរដ្ឋបាលនិងហិរញ្ញវត្ថុ គ.ក.ច.ន.យ

៧- លោក កូយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

៨- លោក ស៊ុន សិរីវុធ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ គ.ក.ច.ន.យ

៩- ឯកឧត្តម នុត សារអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

១០-ឯកឧត្តម ប្រុក សារឿន ក្រសួងមហាផ្ទៃ

១១-ឯកឧត្តម ជុំ ប៊ុនរ៉ុង អគ្គលេខាធិការដ្ឋានរងនៃអគអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតដោះស្រាយទំនាស់ដីធ្លី

១២-លោក ព្រហ្ម វចិត្រអក្ខរា អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតដោះស្រាយទំនាស់ដីធ្លី

១៣-ឯកឧត្តម ឌួង សំភី សមាជិកក្រុមប្រឹក្សាគម្រោង

១៤-ឯកឧត្តម សោម សិរីវឌ្ឍន៍ ចៅក្រមតុលាការកំពូល

១៥-លោកជំទាវ ឆាយ ទ៉ាន់ឡើន

១៦- លោក កុយ នាម សមាជិកប្រឹក្សាគម្រោង ( UNDP )

១៧- លោក កែវ កណ្ណារិទ្ធ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតដោះស្រាយទំនាស់ដីធ្លី

១៨- Ms. Anne-Isabelle-Degryse Blateau

១៩- លោក តែ លី អនុប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ គ.ក.ច.ន.យ